ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ២៦៧ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី : ការអនុវត្តប្រព័ន្ធសហវិមជ្ឈការរបស់ក្រសួងពាណិជ្ជកម្ម នៅតាមបណ្តាខេត្ត-ក្រុង សំរាប់គ្រប់គ្រងរោងចក្រដែលនៅឆ្ងាយ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៩៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ ក្រសួងពាណិជ្ជកម្ម
- យោងស្មារតីអង្គប្រជុំ " ច្រកចេញ-ចូលតែមួយ " នៃ ក.អ."ត.វ.ក" នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០០២ និងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២
- យោងស្មារតីអង្គប្រជុំអន្តរក្រសួង នាថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០២
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ :** ចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៣ តទៅ មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងដែលនៅឆ្ងាយ ចំនួន ០៤ គឺ ខេត្តស្វាយរៀង , ខេត្ត កំពង់ចាម , ខេត្តកំពង់ឆ្នាំង និង ក្រុងព្រះសីហនុ ត្រូវសហការណ៍ ជាមួយមន្ត្រីជំនាញរបស់ក្រសួងដែលបានចាត់តាំងចំនួន ០៤ នាក់ ក្នុងមួយខេត្ត-ក្រុង ដើម្បីអនុវត្តប្រព័ន្ធសហវិមជ្ឈការ សំរាប់គ្រប់គ្រងរោងចក្រ ។

មន្ត្រីជំនាញនេះមានភារកិច្ចជួយបណ្តុះបណ្តាល និង ណែនាំអំពីគោលការណ៍ច្បាប់ប្រភពដើម ទំនិញ (Rules of Origin) និង ច្បាប់ផ្សេងៗទៀតទាក់ទងនឹងការនាំចេញ ។

**ប្រការ ២ :** ក្រុមហ៊ុន ឬរោងចក្រអាចដាក់ពាក្យសុំរបស់ខ្លួននៅមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ដោយផ្ទាល់ ហើយ ទទួលយកវិញនៅទីនោះដដែល ក្នុងរយៈពេល ៤៨ ម៉ោង ស្មើនឹង ០២ ថ្ងៃធ្វើការ ចំពោះឯកសារ ត្រឹមត្រូវ និង គ្រប់គ្រាន់ ។

**ប្រការ ៣ :** មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង មានភារកិច្ចរៀបចំឯកសារនៃការត្រួតពិនិត្យ ផលិតកម្មរោងចក្រ , បំរែបំរួលផលិតកម្ម , របាយការណ៍ត្រួតពិនិត្យទំនិញ និង ស្ថានការណ៍របស់រោងចក្រ ដោយបញ្ជូន ឡើងមកក្រសួង តាមរយៈនាយកដ្ឋានជំនាញ ។

**ប្រការ ៤ :** ក្រៅអំពីខេត្ត-ក្រុង ដូចបានកំណត់ខាងលើ គឺនៅរក្សាស្ថានភាពការងារដដែល រហូតដល់ខេត្ត-ក្រុងឆ្ងាយៗទាំងឡាយនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីដំណើរការប្រព័ន្ធសហវិមជ្ឈការ នេះ ឱ្យមានប្រសិទ្ធភាព ។

**ប្រការ ៥ :** ចំពោះនិតិវិធីនៃការបញ្ជូនឯកសារ-ពត៌មានផ្សេងៗ នាយកដ្ឋានជំនាញ និងមន្ទីរពាណិជ្ជកម្ម ខេត្ត-ក្រុង ត្រូវពិនិត្យដោះស្រាយឱ្យបានល្អប្រសើរគត់ហ្មត់ រក្សាការសម្ងាត់ទៅតាមលទ្ធភាព ដែលអាច ធ្វើទៅបាន ដើម្បីធានាដោតវាសនាអំពីអត្ថប្រយោជន៍ MFN/GSP សំរាប់កម្ពុជា និង ចៀសវាង ការ រាំងស្ទះ ដោយប្រការណាមួយ ប៉ះពាល់ដល់ការនាំចេញរបស់ក្រុមហ៊ុន ឬ រោងចក្រ ។

**ប្រការ ៦ :** កែសំរួលនិតិវិធីមួយចំនួននៃការនាំចេញទំនិញ ដែលមានចែងក្នុងប្រកាសលេខ ០៦០ MoC/M 2002 ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០២ :

ក- ទំនិញនាំចេញតាមនាវា (By Sea) អាចនាំចេញបាន លុះត្រាមាន :



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staffs Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

■ របាយការណ៍របស់មន្ត្រីនាយកដ្ឋានជំនាញនៃក្រសួងពាណិជ្ជកម្ម និង ឧស្សាហកម្ម
■ វិក័យប័ត្រទំនិញ (Invoice) ធ្វើដោយក្រុមហ៊ុន
■ តារាងបញ្ជាក់ការវេចខ្ចប់ (Packing List) ធ្វើដោយក្រុមហ៊ុន

ខ- ទំនិញដែលបាននាំចេញរួចហើយតាមនាវា (By Sea) ក្រុមហ៊ុន ឬ រោងចក្រ អាចសុំយក :

■ វិក័យប័ត្រពាណិជ្ជកម្ម (Commercial Invoice)
■ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin)
■ អាជ្ញាប័ណ្ណនាំចេញ (Export License)

លុះត្រាមានឯកសារយោងដូចខាងក្រោមនេះ :

● វិញ្ញាបនប័ត្របញ្ជាក់បរិមាណទំនិញ (Certificate of Quantity)
● ប្រតិវេទន៍គយ និង រដ្ឋាករ (Customs' Declaration)
● អាញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading)
● វិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម (Certificate of Processing)

គ- ចំពោះទំនិញនាំចេញតាមយន្តហោះ (By Air) ក្រុមហ៊ុនត្រូវមានឯកសារភ្ជាប់ដូចខាងក្រោមនេះ :

● ឯកសារយោង (Airway Bill; Certificate of Quantity; Customs' Declaration) ដែលបាននាំចេញពីមុន បន្ទាប់នៃការស្នើសុំថ្មី
● វិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម (Certificate of Processing)
● វិក័យប័ត្រទំនិញ (Invoice) ធ្វើដោយក្រុមហ៊ុន
● តារាងបញ្ជាក់ការវេចខ្ចប់ (Packing List) ធ្វើដោយក្រុមហ៊ុន
● កិច្ចសន្យាទិញ-លក់ (Sale Contract)
● ការបញ្ជាទិញ (Purchasing Order)

**ប្រការ ៧ :** នាយកខុទ្ទកាល័យ . អគ្គនាយកបច្ចេកទេស . អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ . ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម . ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស . ប្រធាននាយកដ្ឋានកាំកុងត្រូល . ប្រធាននាយកដ្ឋានរដ្ឋបាល ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាព ។



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

**ប្រការ ៨ :** ប្រកាស និង សេចក្តីជូនដំណឹង ដែលមានលក្ខណៈផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងភ្នំពេញ
- សាលាខេត្តស្វាយរៀង
- សាលាខេត្តកំពង់ចាម
- សាលាខេត្តកំពង់ឆ្នាំង
- សាលាក្រុងព្រះសីហនុ
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- សមាគមរោងចក្រស្បែកជើងនៅកម្ពុជា
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

File: Prakas on Decentralized Procedure for remote Industrial Outlets

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: [illegible]